# ជម្ងឺសេះអាហ្វ្រិក

## រោគសញ្ញាដែលត្រូវមើល

រោគសញ្ញាខុសគ្នាតាមប្រភេទសេះក៏ដូចជាសណ្ឋាននៃជម្ងឺនេះ

ប៉ុន្តែរូបភាពនេះបង្ហាញពីរោគសញ្ញាដែលកើតមានឡើងទូទៅច្រើនបំផុត



ហើមជុំវិញភ្នែក ដែលធ្វើឱ្យក្បាលមើលទៅហើមប៉ោង



ភ្នែកក្រហម



ពិបាកដកដង្ហើម និងមានហូរពពុះសំបោរច្រើនចេញពីច្រមុះ

ICWE
INTERNATIONAL COALITION FOR WORKING EQUIDS

BROOKE ACTION FOR WORKING HORSES AND DONKEYS

SPANA

THE DONKEY SANCTUARY

World Horse Welfare

Factsheets and publications: ICWE, www.icweworkingequids.org

# ជម្ងឺសេះអាហ្វ្រិក

## សេះប្រើប្រាស់ជាកំលាំងអូសទាញនៅអាស៊ី ប៉ាស៊ីហ្វិក

ប្រភេទការងារជាទូទៅ ត្រូវបានគេមើលឃើញនៅក្នុងតំបន់បង្ហាញពី
សារៈសំខាន់ដល់ជីវភាពរស់នៅក្នុងតំបន់ និងសេដ្ឋកិច្ច។














សេះប្រើប្រាស់ជាកំលាំងអូសទាញ ជួយទ្រទ្រង់ជីវភាពរស់នៅ ឡឥដ្ឋ ការដឹក ជញ្ជូន ផលិតផល
និងប្រជាជន ប្រមូលកាកសំណាល់ កសិកម្ម និងទេសចរណ៍។

ICWE
INTERNATIONAL COALITION FOR WORKING EQUIDS

BROOKE ACTION FOR WORKING HORSES AND DONKEYS

SPANA

THE DONKEY SANCTUARY

World Horse Welfare

Factsheets and publications: ICWE, www.icweworkingequids.org

# ជម្ងឺសេះអាហ្វ្រិក

## រោគសញ្ញាដែលត្រូវមើលសត្វលារបស់អ្នក

### វាងាយក្នុងការបាត់បង់រោគសញ្ញានៃការឆ្លងទៅលើសត្វលា

ជម្ងឺសេះអាហ្វ្រិក (AHS) បណ្តាលអោយមានរោគសញ្ញាតិច ប្រសិនបើសត្វលា រឺសេះទេសរបស់អ្នកត្រូវបានឆ្លងជម្ងឺ។ រោគសញ្ញាខុសគ្នាអាស្រ័យលើទម្រង់នៃជម្ងឺ និងការរួមបញ្ចូលគ្នានៃសញ្ញាដែលអាចត្រូវបានមើលឃើញ។

ប្រសិនបើអ្នកមើលឃើញសញ្ញាណាមួយក្នុងចំណោមសញ្ញាទាំងនេះ សូមដាក់សត្វលារបស់អ្នកនៅក្នុងក្រោលជាបន្ទាន់។ ត្រូវប្រាកដថាសត្វល្អិតមិនអាចខាំវាបាន ហើយមិនអាចចម្លងជម្ងឺបន្ថែមទៀត។

## រោគសញ្ញាទូទៅបំផុតគឺ៖



សត្វលា និងសេះទេសមើលទៅស្រងូតស្រងាត់



ត្របកភ្នែក និងតំបន់ជុំវិញភ្នែកហើម

*អាចបណ្តាលអោយក្បាលហើម និងភ្នែកក្រហម*



ពិបាកដកដង្ហើម

*រន្ធច្រមុះបើកចំហរទូលាយបង្ហាញពីការខិតខំដកដង្ហើម*

## ក៏អាចមើលឃើញ៖




សីតុណ្ហភាពខ្ពស់ជាង ៣៧,៨ អង្សាសេឬ ១០០.៤ ហ្វារិនហាយ



ខ្សោយ



ហូរពពុះសំបោរចេញពីច្រមុះ

*អាចត្រូវបានគេមើលឃើញមុនពេលស្លាប់*

## ការមើលរោគសញ្ញាដំបូងនៃសុខភាពជម្ងឺ៖



ការស៊ី ឬការផឹកថយចុះ



បំរែបំរួលឥរិយាបថ



ភាពស្ទាក់ស្ទើរក្នុងការផ្លាស់ទី



ទម្រេតខ្លួនបួននៀល

ទាក់ទងពេទ្យសត្វរបស់អ្នក ឬបុគ្គលិកសុខភាពសត្វ ប្រសិនបើសត្វលារបស់អ្នកមើលទៅឈឺ ពួកគេអាចយកសំណាក និងធ្វើតេស្តរកជម្ងឺនេះ។

មិនមានការព្យាបាលទេ ប៉ុន្តែសត្វលាអាចធូរស្បើយដោយការមើលថែទាំបានល្អ។ ផ្តល់កន្លែងសម្រាក អាហារ និងទឹកជម្រក។

ICWE

INTERNATIONAL COALITION FOR WORKING EQUIDS

BROOKE ACTION FOR WORKING HORSES AND DONKEYS

SPANA

THE DONKEY SANCTUARY

World Horse Welfare

# កំណត់សំគាល់ការណែនាំ

*យើងមិនច្បាស់ទេថាតើ សត្វលាអឺរ៉ុប និងអាស៊ីនឹងឆ្លើយតបយ៉ាងដូចម្តេចចំពោះជំងឺសេះអាហ្វ្រិក។*

*ពួកគេហាក់ដូចជាងាយទទួលរងគ្រោះ និងអត្រានៃការស្លាប់១០% ប៉ុន្តែជម្ងឺនេះទើបតែត្រូវបានគេណែនាំថ្មីៗនៅក្នុងតំបន់ ដូច្នេះលទ្ធផលអាចនឹងមិនអាចទាយទុកជាមុនបានទេ។ វាអាចបណ្តាលអោយមានអត្រាស្លាប់ខ្ពស់សូម្បីតែនៅក្នុងសត្វលាព្រោះពួកគេប្រហែលជាមិនមានការប៉ះពាល់  នឹងវីរុសនេះពីមុនមកទេ (ប្រជាជនមិនទាន់មានការយល់ដឹង)។*

*សត្វលាអាចមានរោគសញ្ញាឆ្លងមិនច្បាស់លាស់ ហើយប្រហែលជាមិនត្រូវបានគេធ្វើរោគវិនិច្ឆ័យទេ។ នៅទ្វីបអហ្វ្រិក សត្វលាជារឿយៗត្រូវបានរងផលប៉ះពាល់រោគសញ្ញា និងបង្ហាញរោគសញ្ញាធម្មតានៃ ជម្ងឺស្អួតឬសណ្ឋានចម្រុះនៃជម្ងឺជាមួយនឹងការស្លាប់។*

***រោគសញ្ញាធម្មតារួមមាន៖***

- *ហើមនៅខាងលើភ្នែក រាលដាលទៅត្របកភ្នែក ក្បាល និងក។ អាចមើលទៅហើម។*
- *ភ្នែកក្រហម*
- *ពិបាកដកដង្ហើមដោយមានរន្ធច្រមុះបើកចំហរយ៉ាងធំ*
- *ពពុះ / វត្ថុរាវចេញពីរន្ធច្រមុះនៅដំណាក់កាលចុងក្រោយនៃជម្ងឺ*

*ពួកគេអាចក្តៅខ្លួនហើយអាចបង្ហាញសញ្ញាខ្សោយ។*

*មើលរោគសញ្ញាទូទៅនៃសុខភាពជម្ងឺនៅក្នុងសត្វលា។ សញ្ញាទាំងនេះអាចប្រែប្រួល និងងាយបាត់បង់។*

***សត្វលាឈឺ គួរតែត្រូវបានយកសំណាក និងធ្វើតេស្ត។***

> ***សម្គាល់៖*** *ការរួមបញ្ចូលគ្នានៃការចម្លងរោគជាមួយនឹងជម្ងឺហើមក្រពេញក  និងជម្ងឺរលាកផ្លូវដង្ហើមខាងលើអាចធ្វើអោយរោគសញ្ញាកាន់តែស្មុគស្មាញ ហើយ AHS អាចត្រូវបានខកខាន។ វាចាំបាច់ក្នុងការធ្វើតេស្ត និងចាប់យកពត៌មានអំពីការរីករាលដាលនៃជម្ងឺ។*

# ជម្ងឺសេះអាហ្វ្រិក

## រោគសញ្ញាដែលត្រូវមើលនៅលើសត្វសេះ

### ជម្ងឺធ្ងន់ធ្ងរមួយដែលអាច បណ្ដាលអោយសេះស្លាប់

ជម្ងឺសេះអាហ្វ្រិក (AHS) គឺជាជម្ងឺមួយបង្កឡើងដោយវីរុសក្នុងចំណោមវីរុសភាគច្រើន ដែលធ្វើអោយមានគ្រោះថ្នាក់ដល់ជីវិត។ មានសញ្ញាមួយចំនួនបង្កអោយសត្វដែលឆ្លង ស្លាប់រហូតដល់៩០%។
ប្រសិនបើអ្នកឃើញរោគសញ្ញាណាមួយក្នុងចំណោមរោគសញ្ញាទាំ ងនេះ សូមដាក់សេះរបស់លោកអ្នក នៅក្នុងក្រោលជាបន្ទាន់។ ត្រូវប្រាកដថាសត្វល្អិតមិនអាចខាំ ពួកវា ហើយមិនអាចចម្លងជម្ងឺបន្ថែមទៀត។

## រោគសញ្ញាទូទៅបំផុតគឺៈ




សីតុណ្ហភាពខ្ពស់ជាង
៣៩ អង្សាសេ រឺ ១០២ OF
*ញើសអាចត្រូវបានមើលឃើញ*



ពិបាកដកដង្ហើម
និងក្អកខ្លាំង
*ជាមួយនឹងរន្ធច្រមុះបើកចំហរយ៉ាងធំ*



**ហើមខាងលើ**
**ត្របកភ្នែក**
*ព្រមទាំងមុខ*
*អណ្ដាត និងកផងដែរ*



ភ្នែកក្រហម



ការហូរពពុះសំបោរ
តាមច្រមុះ
*នៅក្នុងដំណាក់កាលចុងក្រោយបង្អស់*

## ការស្លាប់អាចកើតឡើងភ្លាមៗ

**អ្នកប្រហែលជាត្រូវពិចារណាអំពីការសំលាប់ដោយគ្មានការឈឺចាប់**
**ប្រសិនបើសត្វពាហនៈរបស់អ្នកកំពុងតែឈឺចាប់ - ធ្វើតាមការណែនាំរបស់រដ្ឋាភិបាល**

ទាក់ទងពេទ្យសត្វរបស់អ្នក រឺក៏បុគ្គលិកសុខភាពសត្វ ប្រសិនបើសេះរបស់អ្នកមើលទៅឈឺ ពួកគេអាចយកសំណាក និងធ្វើតេស្ត ចំពោះជម្ងឺនេះ។

មិនមានការជាសះស្បើយជាក់លាក់ទេប៉ុន្តែការព្យាបាល ដែលមានការគាំទ្រគួរតែត្រូវបានផ្ដល់ជូន។ អនុញ្ញាតឱ្យសេះសម្រាកនិងផ្ដល់ជម្រក ដាក់មុង ដើម្បីការពារពីសត្វល្អិតខាំ។

ICWE
INTERNATIONAL COALITION FOR WORKING EQUIDS

BROOKE ACTION FOR WORKING HORSES AND DONKEYS
SPANA
THE DONKEY SANCTUARY
WorldHorseWelfare

# កំណត់សម្គាល់ការណែនាំ

ក្នុងចំណោមអំបូលសេះទាំងអស់ សេះស្រុក គឺងាយទទួលរងគ្រោះជាពិសេស និងមានអត្រាស្លាប់ពី៥០-៩៥%។ យើងមិនអាចប្រាកដថា សេះអឺរ៉ុប និងអាស៊ីនឹងឆ្លើយតបយ៉ាងដូចម្តេចចំពោះជម្ងឺសេះអាហ្វ្រិកនោះទេ ប៉ុន្តែជម្ងឺនេះទើបតែត្រូវបានគេណែនាំ ថ្មីទៅក្នុងតំបន់ ដូច្នេះលទ្ធផលអាចនឹងមិនអាចទាយទុកជាមុនបានព្រោះថាពួកគេប្រហែលជាមិនបានដឹងអំពីវីរុសនេះពីមុនទេ (ប្រជាជនមិនមានការយល់ដឹង) ហើយប្រហែលជាមិនអាចគេចផុតពីគ្រោះថ្នាក់ទេ។ អត្រាស្លាប់នៅក្នុងការផ្ទុះឡើងនាពេលបច្ចុប្បន្នមានកំរិតខ្ពស់។

***ជម្ងឺសេះអាហ្វ្រិកត្រូវបានរីករាលដាលតាមរយៈការខាំ នៃសត្វល្អិតដែលឆ្លងវីរុស។*** *សត្វល្អិតបឺតឈាមសំខាន់ដែលផ្ទុកជម្ងឺនេះគឺពពួក មមុង សុច ខុលីខូលឌិស ប៉ុន្តែការខាំ របស់សត្វល្អិតផ្សេងទៀតក៏អាចឆ្លងជម្ងឺនេះបានដែរ។*

*សត្វសេះស្រុកជាធម្មតាផ្ទុកវីរុសនេះរយៈពេលពី៤ ទៅ៨ថ្ងៃប៉ុន្តែវាអាចអូសបន្លាយដល់២១ថ្ងៃ ជាលទ្ធផលក្នុងកំឡុងពេលអូសបន្លាយដែលអាចអោយសត្វល្អិតច្រើនទៀតខាំ  និងក្លាយជាការចម្លងរោគ។*

*សត្វលា និងសេះទេស ក៏ងាយនឹងទទួលរងការកើតជម្ងឺនេះដែរ ហើយគួរតែតាមដានដោយប្រុងប្រយ័ត្នចំពោះរោគសញ្ញាទាំងឡាយនៃសុខភាពជម្ងឺ ព្រោះរោគសញ្ញាទាំងនេះងាយនឹងប្រែប្រួល និងបាត់បង់ខ្លាំងណាស់។*

## *រោគសញ្ញាធម្មតារួមមាន៖*

- *គ្រុនក្តៅដែលកំដៅឡើងខ្ពស់ ហើយបែកញើស*
- *ក្អកខ្លាំង*
- *ហើមនៅជុំវិញក្បាល និងជាពិសេសនៅខាងលើភ្នែក។ ក៏មានឃើញនៅត្រង់ក ផងដែរ ដែលអាចធ្វើអោយវាពិបាកលេបអាហារ។*
- *ការឡើងក្រហមនៃភ្នាសស្តើងអញ្ចាញធ្មេញ និងភ្នែក វាអាចលេចឡើងជាចំនុចក្រហមជាច្រើន។*
- *រោគសញ្ញាជម្ងឺសារ (ឈឺពោះ) ដូចជា ដេកននៀល និងជើងកាយដី*
- *ពិបាកដកដង្ហើមជាមួយនឹងរន្ធច្រមុះបើកចំហរធំ ហើយក ដកវែង។ អត្រានៃការដកដង្ហើមអាចលើសពី៥០ដងក្នុង ១នាទី (សាច់ដុំក្រពះត្រូវបានកំណត់ដោយបង្ខំអោយបញ្ឈប់)។*
- *ការហូរពពុះសំបោរត្រូវបានមើលឃើញចេញពីរន្ធច្រមុះ នៅដំណាក់កាលចុងក្រោយនៃជម្ងឺនេះ ហើយការស្លាប់ជាធម្មតាកើតឡើងក្នុងរយៈពេល២ ទៅ៣ ម៉ោង។*

*គ្រប់ករណីទាំងអស់មិនសុទ្ធតែបង្ហាញរោគសញ្ញាទាំងនេះទេ ហើយរោគសញ្ញាជាច្រើនអាចខុសគ្នាក្នុងសភាពធ្ងន់ធ្ងរ។*

*រោគសញ្ញាបន្ទាប់មួយត្រូវបានមើលឃើញនៅកន្លែងដែលមានភាពស៊ាំ រឺចាក់វ៉ាក់សាំង។ ក្នុងករណីទាំងនេះ  សេះអាចបង្ហាញរោគសញ្ញាគ្រុនក្តៅ ស្រងូតស្រងាត់ និងការកាត់បន្ថយចំណង់អាហារ។ រោគសញ្ញាទាំងនេះមិនកើតឡើងយូរទេ ហើយសេះធម្មតាជាសះស្បើយឡើងវិញក្នុងរយៈពេលពីរបីថ្ងៃ។*

## *អ្វីដែលត្រូវធ្វើប្រសិនបើអ្នកសង្ស័យថាសេះរបស់អ្នកអាចបង្ហាញរោគសញ្ញា៖*

- *ទាក់ទងពេទ្យសត្វ ឬបុគ្គលិកសុខភាពសត្វរបស់អ្នកឱ្យបានឆាប់*
- *អោយសេះរបស់អ្នកសម្រាក*
- *ដាក់សេះ របស់អ្នកនៅក្នុងក្រោល  នៅក្នុងជម្រកមួយដែលត្រូវបានដាក់មុង ការពារពីសត្វល្អិតខាំ។*
- *ចាត់វិធានការបង្ការផ្សេងៗដើម្បីបញ្ឈប់សត្វល្អិតខាំ ដូចជាប្រើថ្នាំបាញ់សត្វល្អិត។*

***សម្គាល់៖*** *ឃ្លាំមើលអោយបានច្បាស់ចំពោះជម្ងឺឆ្លងផ្សេងៗទៀត ដូចជាហើមក្រពេញក ជម្ងឺរលាកផ្លូវដង្ហើមខាងលើ អាចមានន័យថាមិនមែនជា AHS ទេ និងការឆ្លងរោគចូលគ្នាលើសត្វមួយអាចធ្វើអោយរោគសញ្ញាកាន់តែស្មុគស្មាញ។ វាជាការចាំបាច់ក្នុងការធ្វើតេស្ត និងកត់ត្រាពត៌មានអំពីការរីករាលដាលនៃជម្ងឺ។*

# ការពារសេះរបស់អ្នកពី
# ជម្ងឺសេះអាហ្វ្រិក

## របៀបដែលសត្វល្អិតបឺតឈាមចំលងជម្ងឺ៖




ប្រសិនបើអ្នកសង្ស័យថាសេះត្រូវបានឆ្លងជម្ងឺសេះអាហ្វ្រិក (AHS)-
ត្រូវបង្ខាំងទុកវាភ្លាមៗ ដើម្បីការពារពីការចំចម្លងរបស់សត្វល្អិតបឺតឈាម

## ជានិច្ចកាលៈ



**រក្សាសត្វល្អិតអោយនៅខាងក្រៅ**
រក្សាសត្វសេះនៅក្នុងក្រោលចាប់ពីព្រលប់រហូតដល់ព្រលឹម ហើយប្រើសំណាញ់មុងដើម្បីបិទទ្វា និងបង្អួច។



**នៅអោយឆ្ងាយពីសត្វល្អិត**
រក្សាសេះអោយនៅឆ្ងាយពីទឹកដែលមានចំនួនសត្វល្អិតច្រើន។



**ការពារសេះ ពីសត្វល្អិតចំ**
គ្របដណ្តប់សេះ និងបាញ់ថ្នាំសំលាប់សត្វល្អិត រឺទុកដាក់សេះអោយនៅឆ្ងាយពីគេ។



**ប្រយ័ត្នចំពោះការកំពប់ឈាម និងម្ជុលដែលឆ្លង**
កុំប្រើម្ជុលតែមួយលើសេះច្រើន



**បញ្ឈប់ការបំលាស់ទីរបស់សេះ**
ឆ្លងកាត់ចំងាយឆ្ងាយ

រដ្ឋាភិបាលរបស់អ្នកអាចអនុវត្តការចាក់វ៉ាក់សាំង

## សត្វល្អិតបឺតឈាម៖

- មានសកម្មភាពនៅពេលព្រលឹម និងពេលព្រលប់ នេះគឺភាគច្រើននៅពេលដែលពួកវាចំ ។
- ឆាប់ធំធាត់នៅក្នុងបរិយាកាសក្តៅល្មម និងសើម
- ធ្វើដំណើរចម្ងាយឆ្ងាយទៅតាមខ្យល់
- បង្កាត់ពូជនៅក្នុងដីសើម រឺវាលស្មៅ

**អ្នកប្រហែលជាត្រូវពិចារណាអំពីការសំលាប់ដោយគ្មានការឈឺចាប់ប្រសិនបើសេះរបស់អ្នកកំពុងតែឈឺចាប់ - ធ្វើតាមការណែនាំរបស់រដ្ឋាភិបាល។**

INTERNATIONAL COALITION FOR WORKING EQUIDS

# សេចក្ដីណែនាំ

ជម្ងឺសេះអាហ្វ្រិក គឺជាជម្ងឺឆ្លងដែលបណ្ដាលអោយមានគ្រោះថ្នាក់ដល់ជីវិត ដែលមានដើមកំណើតនៅទ្វីបអាហ្វ្រិក និងអាចឆ្លងរាលដាលទៅប្រទេសដទៃទៀត។ វាអាចឆ្លងទៅគ្រប់សេះទាំងអស់។



ជម្ងឺនេះមិនឆ្លង និងមិនឆ្លងរាលដាលដោយទំនាក់ទំនងជិតស្និទ្ធរវាងសេះ និងសេះនោះទេ។ វាបណ្ដាលមកពីវីរុសដែលត្រូវបានដឹកនាំតាមរយៈចម្ងាយឆ្ងាយដោយសត្វល្អិតខាំ។ **សត្វល្អិតដែលឆ្លងបានមកទុំលើសេះ សត្វលា និងសេះទេស ហើយឆ្លងចូលខ្លួនពួកវានៅពេលសត្វល្អិតខាំ។**

**សត្វល្អិតទាំងនេះអាចហោះហើរបានចម្ងាយជាច្រើនម៉ាយ៍ល និងចុះទុំ ហើយរកចំនីលើសេះផ្សេងទៀត ដូចនេះការរីករាលដាលនៃជម្ងឺនេះ គឺមានចម្ងាយឆ្ងាយ។**

សត្វល្អិតខាំសំខាន់ដែលផ្ទុកវីរុសនៃជំងឺសេះអាហ្វ្រិកគឺ សត្វល្អិតបឺតឈាមខុកូលីឌិស ប៉ុន្តែការខាំរបស់សត្វល្អិតដទៃទៀតក៏អាចចម្លងជម្ងឺនេះបានដែរ។

ការការពារការរីករាលដាលជម្ងឺ គួរផ្ដោតសំខាន់លើការការពារពីសត្វល្អិតខាំ។

1. ដើម្បីកាត់បន្ថយទំនាក់ទំនងរវាងការខាំចម្លងរបស់សត្វល្អិតបឺតឈាម និងវីរុសនៃជម្ងឺសេះអាហ្វ្រិក ត្រូវដាក់សេះនៅក្នុងក្រោលនៅពេលយប់ពី ២-៤ម៉ោងមុនពេលថ្ងៃលិច រហូតដល់២-៤ម៉ោងបន្ទាប់ពីថ្ងៃរះ។
2. ផ្ដល់ការការពារបន្ថែមដល់ក្រោលដើម្បីកាត់បន្ថយសត្វល្អិតហើរចូល ដោយប្រើសំណាញ់មុង( ក្រណាត់ជិត៨០%) ដើម្បីបិទបាំងរាល់ការបើក( ឧទាហរណ៍ ការបើកទ្វា និងបង្អួច) នៅពេលយប់។ ក្រណាត់មុងនេះត្រូវបានជ្រលក់ជាមួយ ថ្នាំ សំលាប់សត្វល្អិ តមួយ (Pyrethroid) ។
3. បាញ់ជញ្ជាំងក្រោល និងសំណាញ់មុងការពារ ដោយប្រើថ្នាំសំលាប់សត្វល្អិត (Pyrethroid) មានប្រសិទ្ធិភាពប្រឆាំងនឹងសត្វល្អិតបឺតឈាមខាំ។
4. បាញ់ថ្នាំសំលាប់សត្វល្អិតលើសត្វពាហនៈដែលត្រូវបានចុះឈ្មោះសម្រាប់ប្រើនៅលើសេះនៅពេលរសៀល និងព្រឹកព្រលឹមដោយផ្ដោតលើកន្លែងដែលសត្វល្អិតចូលចិត្តខាំ ដូចជា ក្បាល កញ្ចឹងក ខ្នង និងក្បាលពោះជាដើម។ បាញ់ថ្នាំដែលមានផ្ទុកសាយភើម៉េទ្រីម រឺភើម៉េទ្រីម។ ប៉ុន្តែចំណាំថាសត្វល្អិតនេះនឹងខាំសេះមុនពេលវាត្រូវបានសម្លាប់។
5. លាបថ្នាំសំលាប់សត្វល្អិតអោយសេះទាំងអស់នៅពេលថ្ងៃបាក់រសៀល និងពេលព្រឹកព្រលឹមដោយផ្ដោតទៅលើកន្លែងដែលសត្វល្អិតចូលចិត្តខាំ ដូចជាក្បាល កញ្ចឹងក ខ្នង និងពោះ។ (ប្រើថ្នាំការពារពីសត្វល្អិតDEET រឺផលិតផលធម្មជាតិដូចជា ប្រេងរុក្ខជាតិ និងប្រេង Eucalyptus ត្រួតពិនិត្យមើលប្រតិកម្មស្បែកមិនល្អ។

> **គន្លឹះ៖** យកចិត្តទុកដាក់តាមដានស្បែករបស់សត្វចំពោះការខូចខាត រឺការរលាកដែលបណ្ដាលមកពីថ្នាំសំលាប់សត្វល្អិត។

6. កន្លែងដែលអាចធ្វើទៅបាន សូមផ្លាស់ទីសេះចេញពីកន្លែងបង្កាត់ពូជសត្វល្អិតបឺតឈាម ដូចជាវាលជ្រាំ វាលស្រែ និងតំបន់ភក់។
7. ជៀសវាងការផឹកទឹកនៅទ្រឹង (ទឹកមិនហូរ) ជួសជុលទុយោទឹក និងស្អាចទឹកដែលបែកធ្លាយ ដើម្បីកាត់បន្ថយកន្លែងបង្កាត់ពូជសត្វល្អិតបឺតឈាម។

**រក្សាពត៌មាន និងតាមដានពត៌មានថ្មីៗពីរដ្ឋាភិបាលរបស់អ្នក។**
**សត្វល្អិតខាំផ្សេងទៀតក៏អាចចម្លងជម្ងឺនេះបានដែរ។**
**កុំផ្ដល់សាច់ដែលឆ្លងជម្ងឺទៅសត្វពាហនៈទាំងឡាយ។ ជម្ងឺសេះអាហ្វ្រិកអាចសម្លាប់ឆ្កែបាន។**
**ឈាមអាចផ្ទុកវីរុសបាន។ កុំប្រើម្ជុលដែលប្រើរួច និងធ្វើអោយសត្វល្អិតនៅឆ្ងាយពីឈាមដែលកំពប់។**

## វិធីសាស្ត្រដែលមិនអាចការពារជម្ងឺសេះអាហ្វ្រិកបាន

- ការបង្ហុយផ្សែងជុំវិញក្រោលសេះ។ នេះមិនមានឥទ្ធិពលលើសកម្មភាពសត្វល្អិតនោះទេ។ ហើយវានឹងបង្ករគ្រោះថ្នាក់ដល់មនុស្ស និងសត្វពាហនៈ។
- ថ្នាំសម្លាប់សត្វល្អិតត្រូវបានប្រើដោយខ្លួនឯង។ ការគ្របដណ្ដប់ រឺផ្ដល់ជំរកដល់សេះក្នុងកំឡុងពេលមានហានិភ័យខ្ពស់ក៏ត្រូវការផងដែរ។
- ខ្ទឹមស
- ប្រេងស្លឹកគ្រៃ។ វាអាចទាក់ទាញសត្វទៀតផង។
- ផ្លាស់ទីសេះទៅរយៈកំពស់ខ្ពស់ជាងនេះ។ សត្វល្អិតអាចអត់ធន់នឹងរយៈកំពស់ខ្ពស់ និងការផ្ដល់លក្ខខណ្ឌបរិស្ថានផ្សេងទៀត គឺសមល្មម។